ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តសៀមរាប**

សាលក្រមព្រហ្មទណ្ឌលេខៈ **០៩(ញ្ញ)/១០៩**
ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៣
-សំណុំរឿងព្រហ្មទណ្ឌលេខៈ ៣០៨
ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១
-សំណុំរឿងជំនុំជម្រះលេខៈ ៥៤៧
ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១២

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តសៀមរាប។ សាលសវនាការលេខ ខ១ នាថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣ វេលាព្រឹក។

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តសៀមរាប

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តសៀមរាប

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប

-ជំនុំជម្រះលើបណ្តឹងទាស់ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ របស់ពិរុទ្ធជនឈ្មោះ [redacted] **ប៉័ង** (ឬ [redacted] **ប៉័ង**) ហៅ [redacted] **ប៉័ង** ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខៈ ៣០៨ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] **ចាន់** ភេទប្រុស អាយុ ២៤ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើតភូមិ [redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] សែ "រ" ម្តាយឈ្មោះ [redacted] ពុត "រ" នៅលីវ ប្រវត្តិផ្តន្ទាទោសដោយតុលាការ គ្មាន។

២-ឈ្មោះ [redacted] **សារ៉ាយ** ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរសិស្ស ទីកន្លែងកំណើត [redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] វ៉ង "រ" ម្តាយឈ្មោះ [redacted] ជឹក "រ" នៅលីវ ប្រវត្តិផ្តន្ទាទោសដោយតុលាការ គ្មាន។

៣-ឈ្មោះ [redacted] **ឆលីហៀង** ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករ ទីកន្លែងកំណើតភូមិ [redacted] ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] ៉ា "រ" ម្តាយឈ្មោះ [redacted] ស្រីហ៊ិន "រ" នៅលីវ ប្រវត្តិផ្តន្ទាទោសដោយតុលាការ គ្មាន។

៤-ឈ្មោះ [redacted] **តារំ** ហៅ **ត្រឹម** ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត នៅភូមិ [redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ន ភូមិ [redacted]

[redacted] ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] ហ៊ុល "រ" ម្ដាយឈ្មោះ [redacted] វ៉ាយ "រ" នៅលីវ ប្រវត្តិផ្តន្ទាទោសដោយតុលាការ គ្មាន។

៥-ឈ្មោះ [redacted] **ឆដា** ហៅ [redacted] **ដា** ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិ [redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] ស៊ីវ "រ" នៅលីវ ប្រវត្តិផ្តន្ទាទោសដោយតុលាការ គ្មាន។

៦-ឈ្មោះ [redacted] **វ៉ង** ហៅ [redacted] **វ៉ង** ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិ [redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្នភូមិ [redacted] ប្រាសាទបាគង ខេត្តសៀមរាប។

៧-ឈ្មោះ [redacted] **គឹមឈាង** ហៅ **មុត** ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិ [redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តសៀមរាប។

ជាប់ចោទពីបទៈ **ហិង្សាដោយចេតនាដោយមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិល្អក់ ឃុំកណ្ដែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ។

-**ដើមបណ្ដឹងរដ្ឋប្បវេណីះ**

១-ឈ្មោះ [redacted] **ញ៉ម** ភេទប្រុស អាយុ ៣៤ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន ភូមិគោកត្នោត ឃុំកណ្ដែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប។

២-ឈ្មោះ [redacted] **ប៊ុនថន** ភេទប្រុស អាយុ ៣៤ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន ភូមិគោកត្នោត ឃុំកណ្ដែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប។

-**បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ ៨៤ "ឃ" ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តសៀមរាប។

-**បានឃើញ** ដីកាចាត់តាំងចៅក្រមជំនុំជម្រះលើបណ្ដឹងទាស់លេខៈ ៨៦៥ ពស.ព្រជ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តសៀមរាប។

## <u>អង្គហេតុកើតមានឡើងដូចតទៅ</u>

កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០១១ មានពិធីបុណ្យបញ្ចុះសីមានៅវត្តអារញ្ញនៅក្នុងភូមិល្អក់ ឃុំកណ្ដែក ស្រុកបាសាទបាគង ខេត្តសៀមរាប។ រហូតដល់ម៉ោង ០១ និង ៣០នាទីយប់ ស្រាប់តែមានឈ្មោះ [redacted] សារ៉ាយ, ឈ្មោះ [redacted] ឆលីហៀង, ឈ្មោះ [redacted] ចាន់, ឈ្មោះ [redacted] វ៉ង, ឈ្មោះ [redacted] ឆដា និងឈ្មោះ [redacted] គឹមឈាង បានជិះម៉ូតូចំនួន ០២គ្រឿង មកដល់កន្លែងផ្ញើកង់ម៉ូតូរបស់ឈ្មោះ [redacted] ញ៉ម, ឈ្មោះ [redacted] ប៊ុនថន និងប្អូនប្រុសចំនួន ០២នាក់ទៀត ក៏ស្រែកថា ចង់ដុតកន្លែងផ្ញើកង់ម៉ូតូនោះចោល និងបង្កឲ្យមានការទាស់សំដីគ្នារហូតធ្វើឲ្យឈ្មោះ [redacted] វ៉ង និងបក្ខពួកដូចខាងលើទៅដកដំបងដែលសង់ជិតនោះវាយទៅលើឈ្មោះ [redacted] ញ៉ម ជាច្រើនដំបងបណ្ដាលឲ្យសន្លប់ និងឈ្មោះ [redacted] ប៊ុនថន ត្រូវខ្លួនមិនបណ្ដាលឲ្យសន្លប់ទេ។

សាលក្រមព្រហ្មទណ្ឌលេខ ៨៤(ឃ) ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តសៀមរាប បានសម្រេចៈ

១-ផ្តន្ទាទោសលើៈ

ក-ឈ្មោះ [redacted] វ៉ង ហៅ [redacted] វ៉ង ភេទប្រុស អាយុ ១៨ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០២(ពីរ) ឆ្នាំ គិតចាប់ពីថ្ងៃចាប់យកមកឃុំខ្លួននៅក្នុងពន្ធនាគារតាមអំណាចសាលក្រមនេះ។

ខ-ឈ្មោះ [redacted] ឆដា ហៅ [redacted] ដា ភេទប្រុស អាយុ ១៨ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០២(ពីរ) ឆ្នាំ តែទោសនេះអនុវត្តទោសគុកនៅក្នុងពន្ធនាគាររយៈពេល ០៥(ប្រាំ) ខែ គិតពីថ្ងៃឃុំខ្លួន ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១២ ទោសនៅសល់ពីនេះត្រូវព្យួរធម្មតា។

គ-ឈ្មោះ [redacted] ចាន់ ភេទប្រុស អាយុ ២៤ឆ្នាំ ជនជាតិខ្មែរ

ឃ-ឈ្មោះ [redacted] សារ៉ាយ ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ

ង-ឈ្មោះ [redacted] ឆលីហៀង ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ

ដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ៗ ០២(ពីរ) ឆ្នាំ តែទោសនេះត្រូវអនុវត្តទោសគុកនៅក្នុងពន្ធនាគារ គិតពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ ដល់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ ទោសសល់ពីនេះត្រូវព្យួរធម្មតា។

ច-ឈ្មោះ [redacted] ភារ៉ំ ហៅ ក្រឹម ភេទប្រុស អាយុ ១៨ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០២(ពីរ) ឆ្នាំ តែទោសនេះត្រូវអនុវត្តទោសគុកនៅក្នុងពន្ធនាគារ គិតពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១១ ដល់ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១១ ទោសសល់ពីនេះត្រូវព្យួរធម្មតា។

ពីបទៈ "ហិង្សាដោយចេតនាដោយមានស្ថានទម្ងន់ទោស" ប្រព្រឹត្តនៅភូមិល្អក់ ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា២១៨, មាត្រា១០៧ និងមាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ។

២-ឲ្យឈ្មោះ [redacted] គឹមឈាង រួចខ្លួនពីបទចោទប្រកាន់ពីបទ "ហិង្សាដោយចេតនាដោយមានស្ថានទម្ងន់ទោស" ប្រព្រឹត្តនៅភូមិល្អក់ ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា២១៨, មាត្រា១០៧ និងមាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ។

៣-បង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted] វ៉ង ហៅ [redacted] វ៉ង ដើម្បីយកមកអនុវត្តទោសតាមអំណាចសាលក្រមនេះ។

៤-បញ្ឈប់ដីកាបង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted] គឹមឈាង លេខ ៤៨៤ ពស.ព្រទ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប។

៥-បង្គាប់ឲ្យឈ្មោះ [redacted] ចាន់, ឈ្មោះ [redacted] សារ៉ាយ, ឈ្មោះ [redacted] ឆលីហៀង, ឈ្មោះ [redacted] ឆដា ហៅ [redacted] ដា, ឈ្មោះ [redacted] វ៉ង ហៅ [redacted] វ៉ង និងឈ្មោះ [redacted] ភារ៉ំ ហៅ ក្រឹម រួមគ្នាសងសំណងថ្លៃព្យាបាលរបួស និងជំងឺចិត្តចំនួន ៤.០០០.០០០៛ (បួនលានរៀល) ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ញ៉ម និងចំនួន ៨០០.០០០៛ (ប៉ែតសិបម៉ឺនរៀល) ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនថន។

៦-វត្ថុតាងរួមមានៈ ដំបងឈើប្រវែង ០១ម៉ែត្រ ចំនួន ០៧កំណាត់ និងដំបងឫស្សីចំនួន ០២ កំណាត់ ត្រូវរឹបអូស និងបំផ្លាញចោល។

៧-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងជនជាប់ចោទឈ្មោះ [redacted] ឆដា ហៅ [redacted] ដា, ឈ្មោះ [redacted] ចាន់ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សារ៉ាយ,

ឈ្មោះ [redacted] ឆលីហៀង, ឈ្មោះ [redacted] វ៉ង ហៅ [redacted] វ៉ង, ឈ្មោះ [redacted] ភារំ ហៅ ក្រឹម និងឈ្មោះ [redacted] គឹម ឈាង បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

## <u>នាពេលសវនាការ</u>

-ពិរុទ្ធជនឈ្មោះ [redacted] វ៉ង ហៅ [redacted] វ៉ង បានឆ្លើយថាៈ នៅថ្ងៃកើតហេតុ ពេលខ្លួនត្រឡប់មកពីជូនមិតភក្តិស្រីៗវិញ ខាងជនរងគ្រោះកាក់វាយខ្លួន។ ពេលនោះ ខ្លួនក៏បានកាច់ដើមដំឡូងវាយតបវិញ តែមិនដឹងថាត្រូវអ្នកណាទេ។ ខ្លួនពិតជាបានវាយគេមែន។ ខ្លួនមិនបានឈ្លោះជាមួយ [redacted] ញ៉ម ទេ។ ឈ្មោះ [redacted] ញ៉ម គាត់ដាក់កាវ៉ាស់ម៉ូតូ។ ខ្លួនមិនដឹងថាគាត់ឈ្លោះជាមួយអ្នកណាទេ តែពេលខ្លួនត្រឡប់មកពីជូនស្រីៗវិញ មានគេដេញវាយខ្លួន។ គ្នាគេប្រហែលជា៥ទៅ៦នាក់ដេញវាយខ្លួន ហើយ ខ្លួនក៏ទៅកាច់ដើមដំឡូងវាយតបវិញ។ វាយត្រូវមួយដំបងដើមដំឡូង ហើយ ខ្លួនក៏រត់ទៅផ្ទះ។ ខ្លួនវាយរួចរត់ទៅផ្ទះ ដោយមិនដឹងថាជនរងគ្រោះយ៉ាងម៉េចទេ។ ដំបងដែលខ្លួនវាយនោះគឺខ្លួនដឹងថាជាដើមដំឡូងមី។ ពេលគេដេញវាយខ្លួននោះមានកាន់ដំបងដែរ ហើយ ខ្លួនវាយតបវិញដើម្បីការពារខ្លួនខ្លួនប៉ុណ្ណោះ។ នៅពេលនេះ ខ្លួនដឹងខុសហើយ។ ខ្លួនសុំឲ្យជនរងគ្រោះអត់ទោសឲ្យខ្លួនផង។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ញ៉ម បានឆ្លើយថាៈ នៅថ្ងៃកើតហេតុ ខ្លួនមិនបានរករឿងខាងជនជាប់ចោទមុននោះទេ។ ខ្លួនអត់បានវាយឲ្យគេរបួសនោះទេ។ មុនពេលគេវាយខ្លួននោះ មានរឿងឈ្លោះគ្នាវាយគ្នា តែខ្លួនដេក។ ខ្លួនចងអង្រឹងដេកនៅក្នុងរោង។ ពេលខ្លួនក្រោកពីដេក ហើយ ដើរចេញមកពីរោង ក៏ស្រាប់តែត្រូវគេគប់ខ្លួនត្រូវមួយដំបងបណ្តាលឲ្យដួលសន្លប់។ ខ្លួនមិនដឹងថាអ្នកណាជាអ្នកគប់ទេ។ ក្នុងពាក្យបណ្តឹង ខ្លួនទាមទារសំណង ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក តែស្រេចតែចៅក្រមសម្រេចចុះ។ ក្រោយពេលចេញសាលក្រមមក ខ្លួនមិនទាន់បានទទួលសំណងទេ។

-សាក្សីឈ្មោះ [redacted] គួយ បានឆ្លើយថាៈ ខ្លួនត្រូវជាប្រពន្ធរបស់ឈ្មោះ [redacted] ញ៉ម។ ពេលប្តីទៅពេទ្យ ខ្លួនឃើញប្តីបែកក្បាល និងឃើញគាត់សន្លប់។

-សាក្សីឈ្មោះ [redacted] សំបាន បានឆ្លើយថាៈ ថ្ងៃកើតហេតុពេលខ្លួនភ្ញាក់ពីដេក ឃើញគេវាយបងខ្លួន។ ពេលនោះ ខ្លួនក៏រត់ទៅជួយបងរបស់ខ្លួន ក៏ត្រូវគេវាយខ្លួនទៀត។ ខ្លួនក៏បានស្រែកឲ្យគេជួយ។ ពេលនោះ ពួកអ្នកវាយនោះរត់អស់។ ខ្លួនក៏យកបងរបស់ខ្លួនទៅពេទ្យ។ បងខ្លួនសន្លប់។ ខ្លួនមិនបានស្គាល់អ្នកវាយនោះទេ។ ខ្លួនបានឃើញដំបង។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថាៈ នៅក្នុងរឿងនេះ ក្រោយពីបានស្តាប់ការសួរដេញដោលនៅពេលសវនាការនេះ ឈ្មោះ [redacted] វ៉ង ក៏បានឆ្លើយសារភាពហើយថា ខ្លួនពិតជាបានវាយទៅលើជនរងគ្រោះមែន។ តំណាងអយ្យការមិនមានអ្វីដែលស្នើសុំឲ្យចៅក្រមធ្វើការកែប្រែទៅលើសេចក្តីសម្រេចមុននោះទេ ក៏ប៉ុន្តែ ស្នើសុំឲ្យចៅក្រមពិនិត្យទៅលើអាជ្ញាយុកាលនៃទោស ព្រោះរឿងនេះមានរយៈពេលជាង ១០ឆ្នាំមកហើយ។

-មេធាវីការពារសិទ្ធិឲ្យពិរុទ្ធជនធ្វើសេចក្តីសន្និដ្ឋានៈ កូនក្តីខ្លួនបានសារភាពហើយថា គាត់ពិតជាបានវាយទៅលើជនរងគ្រោះពិតមែន ប៉ុន្តែ ការវាយរបស់កូនក្តីខ្លួនគ្រាន់តែជាការពារខ្លួនរបស់គាត់តែប៉ុណ្ណោះ ដោយសារតែភាគីខាងជនរងគ្រោះបានវាយលើគាត់មុន ហើយមានកាន់ដំបងដែរ។ ម្យ៉ាងវិញទៀត ពេលនោះកូនក្តីរបស់ខ្លួនក៏នៅក្មេង។ ហេតុនេះ ក្នុងនាមខ្លួនជាមេធាវី ស្នើសុំឲ្យលោកចៅក្រម

មេត្តាពិចារណា និងផ្តល់ស្ថានសម្រាលទោសដល់កូនក្តីរបស់ខ្លួន ដោយអនុវត្តទោសពន្ធនាគារត្រឹមតែថ្ងៃប្រកាសសាលក្រម ដោយសារកូនក្តីខ្លួនត្រូវរៀបអាពាហ៍ពិពាហ៍ក្នុងកំឡុងខែកុម្ភៈ ឆ្នាំ២០២៣ នេះ។

-ពិរុទ្ធជនឈ្មោះ [redacted] វ៉ង បាននិយាយសំដីចុងក្រោយថាៈ សូមតុលាការបន្ធូរបន្ថយទោសឲ្យដល់ខ្លួនផង។ ខ្លួនដឹងខុសហើយ។

**ក្រោយពីបានពិនិត្យ និង ពិចារណាអង្គហេតុ តស្តុតាង និង សំណូមពររបស់ភាគី**

**សំអាងហេតុ**

១/-យល់ឃើញថាៈ ពាក្យបណ្តឹងទាស់ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] វ៉ង ហៅ [redacted] វ៉ង ធ្វើឡើងត្រឹមត្រូវតាមច្បាប់។ តុលាការអាចលើកយកសំណុំរឿងមកជំនុំជម្រះជាថ្មីម្តងទៀតតាមបញ្ញត្តិមាត្រា៣៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២/-យល់ឃើញថាៈ ដីកាសំណោះស្រាយបញ្ជូនសំណុំរឿងព្រហ្មទណ្ឌទៅជំនុំជម្រះលេខ ៧៥៨៧ ពស/ព្រទ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១២ បានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] វ៉ង ហៅ [redacted] វ៉ង ទៅជំនុំជម្រះពីបទ "ហិង្សាដោយចេតនាដោយមានស្ថានទម្ងន់ទោស" ប្រព្រឹត្តនៅភូមិល្អក់ ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ។

៣/-យល់ឃើញថាៈ សាលក្រមព្រហ្មទណ្ឌលេខ ៨៤(យ) ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តសៀមរាប បានសម្រេចផ្តន្ទាទោសឈ្មោះ [redacted] វ៉ង ហៅ វ៉ាន់ វ៉ង ភេទប្រុស អាយុ ១៨ ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០២(ពីរ) ឆ្នាំ ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិល្អក់ ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ។

៤/-យល់ឃើញថាៈ មាត្រា២១៨ (ស្ថានទម្ងន់ទោស) នៃក្រមព្រហ្មទណ្ឌបញ្ញត្តថា អំពើហិង្សាដោយចេតនាត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០២(ពីរ) ឆ្នាំ ទៅ ០៥(ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល កាលបើអំពើហិង្សានេះបានប្រព្រឹត្តៈ ១-ដោយមានការគិតទុកជាមុន ២-ដោយប្រើអាវុធ ឬ គំរាមកំហែងនឹងអាវុធ ៣-ដោយមានមនុស្សច្រើននាក់ក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត និងជាអ្នកសមគំនិត។

៥/-យល់ឃើញថាៈ នាពេលសវនាការ ពិរុទ្ធជនឈ្មោះ [redacted] វ៉ង ហៅ [redacted] វ៉ង បានសារភាពថា ខ្លួនពិតជាបានវាយទៅលើជនរងគ្រោះ ដោយប្រើដំបងជាអាវុធ និងមានអ្នកចូលរួមច្រើនក្នុងនាមជាសហចារីប្រាកដមែន។ ចម្លើយរបស់ពិរុទ្ធជននៅពេលសវនាការ មានភាពស៊ីសង្វាក់ទៅនឹងចម្លើយរបស់ជនជាប់ចោទផ្សេងទៀត ចម្លើយរបស់ជនរងគ្រោះ ចម្លើយរបស់សាក្សី និងភស្តុតាងនានានៅក្នុងសំណុំរឿង ដែលអាចបញ្ជាក់ថាៈ ពិរុទ្ធជនរូបនេះពិតជាបានប្រព្រឹត្តបទល្មើស ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ដូចការចោទប្រកាន់មែន។

៦/-យល់ឃើញថាៈ ពិរុទ្ធជនឈ្មោះ [redacted] វ៉ង ហៅ [redacted] វ៉ង គឺជានីតិជន មានសមត្ថភាពយល់ដឹង និងស្មារតី អាចវិនិច្ឆ័យអំពីអំពើ និងលទ្ធផលតាមផ្លូវច្បាប់នៃអំពើរបស់ខ្លួន ហើយពិរុទ្ធជនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត។

៧/-យល់ឃើញថា៖ មានពិរុទ្ធភាពគ្រប់គ្រាន់ និងលើសពីវិមតិសង្ស័យ លើពិរុទ្ធជនឈ្មោះ [redacted] វ៉ង ហៅ [redacted] វ៉ង ពីបទ "ហិង្សាដោយចេតនាដោយមានស្ថានទម្ងន់ទោស" ប្រព្រឹត្តនៅភូមិល្អក់ ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ។ គប្បីតុលាការសម្រេចផ្តន្ទាទោសឈ្មោះ [redacted] វ៉ង ហៅ [redacted] វ៉ង តាមច្បាប់។

៨/-យល់ឃើញថា៖ នាពេលប្រព្រឹត្តបទល្មើស ឈ្មោះ [redacted] វ៉ង ហៅ [redacted] វ៉ង មានអាយុទើបតែ ១៨ ឆ្នាំ ដែលជាវ័យនៅក្មេងនៅឡើយ។ ស្ថិតនៅក្នុងវ័យនេះ ពិរុទ្ធជនមានការយល់ដឹងនៅមានកម្រិត ហើយ ការគិតគូរមិនបានគ្រប់ជ្រុងជ្រោយ ខ្វះចំណេះដឹង និងខ្វះបទពិសោធន៍។ ម្យ៉ាងវិញទៀត បើគិតមកដល់ពេលសវនាកនេះ ពេលវេលាបានកន្លងហួសរយៈពេល ១១ឆ្នាំ ៩ខែ ៥ថ្ងៃ មកហើយ។ ជាងនេះទៅទៀត នាពេលសវនាការ ពិរុទ្ធជនមានការភ្ញាក់រលឹកដឹងកំហុស ដែលខ្លួនបានប្រព្រឹត្តនាពេលកន្លងមក និងបានសុំទោសជនរងគ្រោះនាពេលសវនាការ ដែលបង្ហាញឲ្យឃើញថា ពិរុទ្ធជនពិតជាមានឆន្ទៈពិតប្រាកដក្នុងការកែប្រែខ្លួនឲ្យក្លាយជាពលរដ្ឋល្អ ដើម្បីចូលរួមរស់នៅក្នុងសង្គមវិញ។ តុលាការ គួរពិនិត្យ និងពិចារណាផ្តល់ស្ថានសម្រាលទោសដល់ពិរុទ្ធជន។

៩/-យល់ឃើញថា៖ តាមគោលការណ៍សមទណ្ឌ ដែលមានចែងនៅក្នុងក្រមសីលធម៌ចៅក្រមតុលាការត្រូវប្រកាសទោស ឬ ទណ្ឌកម្មទៅលើជនដែលប្រព្រឹត្តអំពើល្មើសដូចគ្នា ត្រូវមានសមភាពគ្នា។ គប្បីតុលាការប្រកាសទោសលើពិរុទ្ធជនឈ្មោះ [redacted] វ៉ង ហៅ [redacted] វ៉ង ឲ្យមានសមភាពទៅនឹងទោសដែលបានប្រកាសចំពោះពិរុទ្ធជនផ្សេងទៀត។

១០/-យល់ឃើញថា៖ តំណាងអយ្យការបានស្នើសុំឲ្យពិនិត្យទៅលើអាជ្ញាយុកាលនៃទោសពីព្រោះរឿងនេះមានរយៈពេលជាង ១០ឆ្នាំមកហើយ។ តុលាការពិនិត្យឃើញថា សាលក្រមព្រហ្មទណ្ឌលេខ ៨៤ (យ) ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តសៀមរាប ពុំទាន់បានចូលជាស្ថាពរចំពោះពិរុទ្ធជនឈ្មោះ [redacted] វ៉ង ហៅ [redacted] វ៉ង នេះនៅឡើយទេ។ ដូច្នេះ អាយុកាលនៃទោសដែលត្រូវទទួលខុសត្រូវដោយពិរុទ្ធជនក៏មិនទាន់ផុតរលត់នៅឡើយដែរ យោងតាមមាត្រា១៤៤ និងមាត្រា១៤៥ នៃក្រមព្រហ្មទណ្ឌ។

១១/-យល់ឃើញថា៖ មេធាវីការពារសិទ្ធឲ្យពិរុទ្ធជន បានធ្វើសេចក្តីសន្និដ្ឋានការពារជាលាយលក្ខណ៍អក្សរចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣ និងបានស្នើសុំឲ្យតុលាការពិចារណា និងផ្តល់ស្ថានសម្រាលទោសដល់ពិរុទ្ធជន ដោយអនុវត្តទោសពន្ធនាគារត្រឹមតែថ្ងៃប្រកាសសាលក្រម ដោយសារពិរុទ្ធជនត្រូវរៀបអាពាហ៍ពិពាហ៍ក្នុងកំឡុងខែកុម្ភៈ ឆ្នាំ២០២៣។ គប្បីតុលាការពិចារណាតាមច្បាប់។

## ហេតុដូច្នេះសម្រេច

**១**/-ទទួលបណ្តឹងទាស់ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] វ៉ង (ឬ [redacted] វ៉ង) ហៅ [redacted] វ៉ង ភេទប្រុស ទុកជាត្រឹមត្រូវតាមច្បាប់ ដែលសាលាដំបូងខេត្តសៀមរាបអាចលើកយកសំណុំរឿងមកជំនុំជម្រះជាថ្មីម្តងទៀត តាមបញ្ញត្តិមាត្រា៣៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**២**/-កែប្រែសេចក្តីសម្រេច ត្រង់ចំណុច ១ (ក) នៃសាលក្រមព្រហ្មទណ្ឌលេខ ៨៤ "យ" ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តសៀមរាប ដោយសម្រេចជាថ្មី ដូចខាងក្រោម៖



Scanned with CamScanner

-ផ្តន្ទាទោសឈ្មោះ [redacted] វ៉ង (ឬ [redacted] វ៉ង) ហៅ [redacted] វ៉ង ភេទប្រុស អាយុ ១៨ឆ្នាំ ដាក់ពន្ធនាគារ កំណត់ ០២(ពីរ) ឆ្នាំ ដោយអនុវត្តទោសក្នុងពន្ធនាគាររយៈពេល ០៤(បួន) ខែ ហើយទោសដែលនៅសល់ត្រូវព្យួរធម្មតាពីបទ "ហិង្សាដោយចេតនាដោយមានស្ថានទម្ងន់ទោស" ប្រព្រឹត្តនៅភូមិល្អក់ ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ។

៣/-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៨៤ "ឃ" ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តសៀមរាប ត្រង់ចំណុច៥ នៃសេចក្តីសម្រេច ទុកជាបានការដដែល។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈ កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៣ ចំពោះមុខពិរុទ្ធជនឈ្មោះ [redacted] វ៉ង (ឬ [redacted] វ៉ង) ហៅ [redacted] វ៉ង។ បើកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា: [redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា: [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃពុធ ៣រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅសៀមរាប, ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៣
**ក្រឡាបញ្ជី**
[redacted]

បានឃើញ
**ចៅក្រមជំនុំជម្រះ**
[redacted]